# ព្រះរាជក្រម

នស/ រកម / ០៧០៤ / ០០១

យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃ រដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃ ព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

# ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់ធម្មនុញ្ញបន្ថែម
# សំដៅ
# ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

**មាត្រា ១.-**

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមស្របតាមតំរូវការនៃភាពចាំបាច់ ។

**មាត្រា ២.-**

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្ដើមការងាររបស់ខ្លួន និង ក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្ដើមអនុម័ត អត្ថបទដែលមានចារិក ជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

**មាត្រា ៣.-**

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើររបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការក្នុងពេលជាមួយគ្នា និង ការផ្ដល់សេចក្ដីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

**មាត្រា ៤.-**

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និង ផ្តល់សេចក្តីទុកចិត្ត ត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និង ស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមា.ជិករដ្ឋសភា ។

- តាមសេចក្តីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។

រជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជី រាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

**មាត្រា ៥.-**

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬ មិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

**មាត្រា ៦.-**

ការបោះឆ្នោតជាគញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

**មាត្រា ៧.-**

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ញឹក ប៊ុនឆៃ

ពរល.០៤.០៧.១១៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

ព្រឹទ្ធសមាជិក និង ជាប្រធានអង្គប្រជុំរដ្ឋសភា

ហត្ថលេខា

ជា សុទ្ធ

លេខ: ៩០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងី តាន់